មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0038

# សម្ភាសន៍ជាមួយឈ្មោះ គីម ម៉ាន ភេទស្រី អាយុ៥៧ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កម្មកររោងចក្រគ-១ និង

## ប្រធានផ្នែកព័ន្ធដែកនៅរោងចក្រគ្រឿង

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិត្រពាំងបោះ ឃុំអណ្តូងពោធិ៍ ស្រុករមាសហែក ខេត្តស្វាយរៀង

## សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ហ៊ិន សុធានី

## ០១:០១:៤៧

## ២៧ទំព័រ

ធានី ៖ ថ្ងៃនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះចង់សាកសួរមីងពីប្រវត្តិរបស់មីង ពីការរស់នៅរបស់មីងយ៉ាងម៉េចតាំងពីដំបូងរហូតមកដល់ឥឡូវនៅស្រុកម៉ាឡៃនេះ ។ តើការកកើតនឹងវាយ៉ាងម៉េច មានការលំបាកអីខ្លះកើតឡើង ហើយប្រវត្តិទាំងនេះ ពួកខ្ញុំយកមកធ្វើជាសៀវភៅសម្រាប់កូនសិស្ស ឬក្មេងៗជំនាន់ក្រោយ អ្នកស្រាវជ្រាវផ្សេងៗ គាត់យកមកស្រាវជ្រាវ ដើម្បីយកមកសិក្សាសម្រាប់ក្មេងក្រោយៗបានអាន បានដឹងពីរឿងនឹងដែរ ។

ម៉ាន ៖ ចា៎ស!

ធានី ៖ ខ្ញុំសុំថតជាសម្លេង ក៏ដូចជាថតរូបមីងអីចឹងបានទេ?

ម៉ាន ៖ បានមិនអីទេ ។

ធានី ៖ មីនមានឈ្មោះអីគេ?

ម៉ាន ៖ ខ្ញុំឈ្មោះ គីម ម៉ាន ។

ធានី ៖ មីងមានឈ្មោះហៅក្រៅទេ?

ម៉ាន ៖ អត់ ។

ធានី ៖ នៅស្រុកភូមិក៏អត់មាន?

ម៉ាន ៖ ចា៎ស! អត់ ឲ្យឈ្មោះប្រើតែឈ្មោះនឹងមួយទៅ ។

ធានី ៖ មីងមានអាយុប៉ុន្មានហើយ?

ម៉ាន ៖ ៥៥ ។

ធានី ៖ អាយុគំណាងមីងរី(សូ រី សម្មាសន៍) ដែរ?

ម៉ាន ៖ អឺ! អាយុគំណាងអ៊ីរីនឹង៦៨ ។

ធានី ៖ មីងអាយុ៥៥ ៥៣ ឬ៥៧?

ម៉ាន ៖ ៥៧ ។

ធានី ៖ មីងមានស្រុកកំណើតនៅណាដែរ?

ម៉ាន ៖ ស្រុកកំណើតខ្ញុំនៅស្វាយរៀង ។

ធានី ៖ នៅភូមិឃុំស្រុកអូដែរ?

ម៉ាន ៖ ស្រុករមាសហែក ។

ធានី ៖ ភូមិអីគេ?

ម៉ាន ៖ ភូមិត្រពាំងបោះ ។

ធានី ៖ ឃុំអីគេ?

ម៉ាន ៖ ឃុំអណ្តូងពោធិ៍ ។

ធានី ៖ ឃុំអណ្តូងពោធិ៍?

ម៉ាន ៖ ចា៎ស!

ធានី ៖ សព្វថ្ងៃមីងរស់នៅណាដែរ នៅភូមិឃុំស្រុកខេត្តណា?

ម៉ាន ៖ នៅបន្ទាយមានជ័យ ។

ធានី ៖ នៅភូមិអីគេ?

ម៉ាន ៖ នៅភូមិកណ្តាល ស្រុកម៉ាឡៃ ឃុំម៉ាឡៃ ។

ធានី ៖ ឪពុកមីងឈ្មោះអី?

ម៉ាន ៖ ឪពុកខ្ញុំឈ្មោះ គីម អ៊ិន ។

ធានី ៖ គាត់នៅរស់ទេ?

ម៉ាន ៖ ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណា?

ម៉ាន ៖ ស្លាប់តាំងពីយូរហើយ តាំងពីខ្ញុំនៅតូចៗ ។

ធានី ៖ ចាំឆ្នាំទេ ពេលនឹងមីងអាយុប៉ុន្មានឆ្នាំ?

ម៉ាន ៖ អាយុប្រហែលជា១០ឆ្នាំជាង ប៉ុន្តែអត់ចាំទេ មិនដឹងប៉ុន្មាន ។

ធានី ៖ ចុះម្តាយឈ្មោះអីគេ?

ម៉ាន ៖ ម្ដាយឈ្មោះ សូ សិទ្ធិ ។

ធានី ៖ គាត់?

ម៉ាន ៖ ស្លាប់អស់ហើយ ។

ធានី ៖ ស្លាប់ឆ្នាំប៉ុន្មាន?

ម៉ាន ៖ មិនដឹងឆ្នាំប៉ុន្មានទេ ព្រោះខ្ញុំចេញមកបាត់ហើយ ។

ធានី ៖ មីងដឹងថាគាត់ស្លាប់ពេលណាទេ?

ម៉ាន ៖ ប្អូនប្រាប់ដែរ ប៉ុនមិនចាំ ។

ធានី ៖ សម័យយើងឥឡូវ ឬក៏ម៉េច?

ម៉ាន ៖ ពូប្អូនខ្ញុំថាសម័យអ៊ុន គាត់ចូល ។

ធានី ៖ ដោយសារអីគេ?

ម៉ាន ៖ គាត់ជម្ងឺគាត់ចាស់ ។

ធានី ៖ ចុះឪពុក?

ម៉ាន ៖ ឪពុកគាត់ចាស់ ។

ធានី ៖ បងប្អូនប៉ុន្មាននាក់?

ម៉ាន ៖ បងប្អូនខ្ញុំ៧នាក់ ។

ធានី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ម៉ាន ៖ ស្រី២ ប្រុស៥ ។

ធានី ៖ គាត់នៅរស់ទាំងអស់?

ម៉ាន ៖ រស់ទាំងអស់ ។

ធានី ៖ នៅណាវិញរាល់ថ្ងៃពួកគាត់?

ម៉ាន ៖ អូ! បងប្អូននៅសល់តែ៣នាក់ សល់ប្រុស១ ស្រី២ ។

ធានី ៖ ហេតុអីបានសល់តែ៣?

ម៉ាន ៖ អឺ! កាលនៅសង្គ្រាមប្អូន មិនដឹងជាយ៉ាងណា យ៉ាងណៃ គេធ្វើទាហាន ធ្វើទ័ពអីទៅបែកគ្នារហូត ។

ធានី ៖ អត់ដឹងដែរ?

ម៉ាន ៖ អត់ដឹង ស្លាប់នឹងសង្គ្រាមនឹងម៉ង ។

ធានី ៖ មីងថាម្ដាយមីងបែកពីមីងម៉េច មីងបែកចេញពីម្ដាយមីងយូរហើយម៉េច?

ម៉ាន ៖ តាំងពី៧៣ ។

ធានី ៖ ទៅណា បែកពីម្តាយ?

ម៉ាន ៖ មក៧៣នឹង គឺមកធ្វើកងទ័ពនារី ។

ធានី ៖ កងទ័ពនារីនៅណាវិញ?

ម៉ាន ៖ នៅបូព៌ា ។

ធានី ៖ បូព៌ា នៅភូមិឃុំអីដែរ?

ម៉ាន ៖ ភូមិភាគបូព៌ា ម្តុំកញ្ច្រៀច ។

ធានី ៖ មីងធ្វើជាអីគេដែរនៅនឹង?

ម៉ាន ៖ ធ្វើកងទ័ព ។

ធានី ៖ មុខងារជាអីគេ?

ម៉ាន ៖ ធ្វើជាកូនទាហានគេ ។

ធានី ៖ ខាងនារី?

ម៉ាន ៖ ខាងនារី កាលនឹងគេហៅកងទ័ពនារី ។

ធានី ៖ អ្នកណាគេប្រធានកងទ័ពនារី?

ម៉ាន ៖ បងសាម ។

ធានី ៖ បងសាម ជាអ្នកណា?

ម៉ាន ៖ មិនដឹងគាត់នៅស្រុកណា ។

ធានី ៖ គាត់ជានារីៗអីគេ នារីតំបន់ នារីស្រុក?

ម៉ាន ៖ នារីភូមិភាគ ។

ធានី ៖ នារីភូមិភាគបូព៌ា?

ម៉ាន ៖ ចាស!

ធានី ៖ នារីប្រចាំស្រុកកញ្ច្រៀចនឹង?

ម៉ាន ៖ គេថានៅនឹងភូមិភាគនឹងម៉ង ។

ធានី ៖ ភូមិភាគបូព៌ានឹង?

ម៉ាន ៖ ចាស! ខ្ញុំនៅតូចដែរ គេថាភូមិភាគៗនឹងគេ ។

ធានី ៖ បងសាមនឹងជានារីភូមិភាគនឹង ជាប្រធានរបស់?

ម៉ាន ៖ ចាស!

ធានី ៖ បន្ទាប់មកម៉េចទៀត?

ម៉ាន ៖ បន្ទាប់មកចេះហាត់បាន៣ឆ្នាំ ។ ដល់មកឆ្នាំ៧៥ យើងរំដោះទីក្រុងភ្នំពេញ ។ បានចូលមកទីក្រុងភ្នំពេញ ធ្វើកម្មករនៅកន្លែងរោងចក្រ ។

ធានី ៖ កម្មកររោងចក្រអីគេ?

ម៉ាន ៖ រោងចក្រ កាលនឹងរោងចក្រត-១តម្បាញក្រណាត់ ។

ធានី ៖ នៅណាវិញ?

ម៉ាន ៖ នៅម្ដុំពោធិ៍ចិនតុង ។

ធានី ៖ ត-១នៅពោធិ៍ចិនតុង?

ម៉ាន ៖ ចាស!

ធានី ៖ ហើយអ្នកណាគេប្រធានរោងចក្រ?

ម៉ាន ៖ ឈ្មោះ ហ៊ាន ។

ធានី ៖ ហ៊ាន ស្រី ឬប្រុស?

ម៉ាន ៖ ប្រុស ។

ធានី ៖ កាលពេលមីងធ្វើទាហានហាត់២ឆ្នាំ មីងទៅណាទៀត ព្រោះឆ្នាំ៧៣-៧៤បាន២ឆ្នាំ ។ ហាត់ទាហានអត់មានបានប្រយុទ្ធជាមួយគេណា?

ម៉ាន ៖ អត់ទេ គ្រាន់ហាត់ៗទៅ គេខាងប្រុសៗនឹង គេវ៉ៃរំដោះទីក្រុងភ្នំពេញនឹង ពួកខ្ញុំចូលមករៀបទីក្រុងភ្នំពេញ ។ រៀបទីក្រុងភ្នំពេញ គ្រាន់ថាដូចថាជម្លៀសប្រជាជនតាមផ្លូវថ្នល់ យើងយាមនៅនឹងកែងថ្នល់ កុំឲ្យគាត់ដើររសេបរសាប អ្នកគេបញ្ជូនលិច យើងយាមកែងថ្នល់ យើងមិនដឹងរឿង គ្រាន់យាមៗប៉ុណ្ណោះ ។

ធានី ៖ យាមកែងថ្នល់ខាងណា?

ម៉ាន ៖ ខាងក្បាលថ្នល់ ។

ធានី ៖ ម្ដុំក្បាលថ្នល់?

ម៉ាន ៖ ចាស! ទៅតាខ្មៅ ។

ធានី ៖ យាមនឹងយាមយ៉ាងម៉េច?

ម៉ាន ៖ យាម២នាក់ ម្ខាងផ្លូវម្នាក់ គ្រាន់ថាឲ្យដើរទៅត្រង់ផ្លូវទៅនឹងទៅ កុំឲ្យបែកទៅណាទៅណែ ។

ធានី ៖ មីងឃើញទិដ្ឋភាពនឹងម៉េចដែរ?

ម៉ាន ៖ ឃើញទិដ្ឋភាពនឹង វាដូចថាចាកផ្ទះសម្បែងទាំងគេទាំងយើង ចុះចេញពីផ្ទះសម្បែងធំទៅស្ដាយស្រណោះដូចគ្នា តែមិនដឹងធ្វើម៉េច ។

ធានី ៖ ប៉ុន្មានថ្ងៃបានគេចេញអស់?

ម៉ាន ៖ ប្រហែលជាម៉ាអាទិត្យ ។

ធានី ៖ ម៉ាអាទិត្យអស់ពីភ្នំពេញ?

ម៉ាន ៖ អស់ ។ នឹងរៀបចំកម្មករសារថ្មី ។

ធានី ៖ រៀបម៉េច?

ម៉ាន ៖ ដូចថាទុកមេជាងចាស់១២-៣នាក់ នៅអប់រំក្មេងក្តាប់នៅកន្លែងរោងចក្រនឹង កន្លែងធ្វើអីផ្សេងៗ ។ អីចឹងបានថាឲ្យដឹកនាំកម្មករថ្មីសារឡើងវិញ ដែលយើងក្តោបក្តាប់បាន យើងក៏ឲ្យគាត់នៅនឹងឯង យើងធ្វើការនឹងរហូតទាល់តែដល់យើងមានសង្គ្រាមសារថ្មីទៀត ៣ឆ្នាំនឹង ។

ធានី ៖ កាលពេលមីងនៅរោងចក្រនឹង មីងធ្វើជាងារជាស្អីដែរ?

ម៉ាន ៖ តម្បាញ កាន់គីតម្បាញ ។

ធានី ៖ ប្រធានកាន់គីតម្បាញ?

ម៉ាន ៖ អត់ប្រធានទេ ។

ធានី ៖ ត្បាញម៉េង?

ម៉ាន ៖ ត្បាញយកៗ ឲ្យយើងបើកម៉ាស៊ីនទៅ អ្នកផ្នែកគេដាក់ត្រល់នោះផ្សេងទៅ ហើយយើងឈរតែបញ្ជាម៉ាស៊ីន ។ ដល់ពេលដាច់អំបោះដាច់អីទៅ យើងចាក់ធ្មេញត្រករអីទៅ យើងដាក់មកវិញមក បើកម៉ាស៊ីនសារថ្មីទៀតទៅ ។

ធានី ៖ អ្នកមានកាន់ត្រល់ផ្សេងទៀតទៅ?

ម៉ាន ៖ ត្រល់អ្នកដាក់ក្នុងប្រអប់ក្នុងម៉ាស៊ីននឹង ម៉ាស៊ីនកីនឹង ដល់ពេលវាអស់វាមកចូលផ្លាស់ខ្លួនឯង ។

ធានី ៖ យើងប្រើតម្បាញនឹង តម្បាញម៉ាស៊ីន មិនមែនតម្បាញដៃ?

ម៉ាន ៖ អត់ទេ តម្បាញម៉ាស៊ីន ។

ធានី ៖ កាលនឹងមីងនិយាយថា កាលពេលជម្លៀសប្រជាជនរយៈពេលម៉ាទិត្យ ហើយមីងរៀបចំកន្លែងរៀបចំទីក្រុងម៉េច?

ម៉ាន ៖ រៀបចំៗតម្បាញអីនឹង គ្រប់ផ្នែកទាំងអស់ មានក្តារបន្ទះ យើងធ្វើជាបាឡុង គ្រប់ស្ថាប័នទាំងអស់ គេរៀបចំនឹងឯង ។

ធានី ៖ រៀបនៅក្នុងទីក្រុងនឹង?

ម៉ាន ៖ ចាស! ដូចថាកន្លែងណាតម្បាញដាក់តម្បាញទៅ កន្លែងណាទឹកក្រូចគេដាក់ទឹកក្រូច កន្លែងណាអគ្គីសនីគេដាក់អគ្គីសនីតាមផ្នែកគេរហូត ។

ធានី ៖ ហើយគេយកខាងណាមកខ្លះ?

ម៉ាន ៖ យកក្នុងជួរទ័ព ។

ធានី ៖ ជួរទ័ពទាំងអស់ ទាំងស្រីទាំងប្រុស?

ម៉ាន ៖ ចាស! ទាំងស្រីទាំងប្រុស គេរំសាយមកពីទ័ពខ្លះមក នៅក្នុងកងទ័ពនឹងការពារក្នុងទីក្រុង នឹងខ្លះយកទ័ពដែលចំណាយក្នុងទ័ពនឹង យកមកកាន់នៅកន្លែងការងារកសិកម្មខ្លះ ។

ធានី ៖ គេបែកទាំងគ្រប់ផ្នែក ច្រើនទេ មីងទ័ពទាំងអស់?

ម៉ាន ៖ ច្រើនៗ ចុះម៉ាប្រទេសកម្ពុជាគិតមើលចូលទៅ ។

ធានី ៖ ហើយគេយកទៅធ្វើរោងចក្រខ្លះ ការពារខ្លះ?

ម៉ាន ៖ បែកចាយគ្រប់មុខក្រសួងទាំងអស់ ។

ធានី ៖ កាលនឹងមានប៉ុន្មានមុខក្រសួង?

ម៉ាន ៖ អូ! ច្រើនណាស់ មិនដឹងស្អីខ្លះទេ ។

ធានី ៖ ចុះម៉េចមីងដឹងថាមានតម្បាញ មានក្តារបន្ទះ មានអគ្គីសនីណានោះ?

ម៉ាន ៖ មានៗ នៅជិតៗគ្នា ។

ធានី ៖ នៅក្បែររោងចក្រមីងដែរ?

ម៉ាន ៖ ចាស!

ធានី ៖ រោងចក្រមីងមានអីខ្លះ?

ម៉ាន ៖ នៅជិតគ្នា តាំងអំពីអំបោះហុង តាំងពីភួយ ធ្វើទឹកក្រូច រោងចក្រទឹកកក ។

ធានី ៖ ហើយទៅស្នាក់នៅណា?

ម៉ាន ៖ ស្នាក់នៅនឹងឯង នៅរោងចក្រ មានផ្ទះកម្មកររោងចក្រមុននៅនឹង ។

ធានី ៖ រោងចក្រមីងមានគ្នាប៉ុន្មាននាក់?

ម៉ាន ៖ ប្រហែលជា៥០០ រោងចក្រនឹងច្រើន គេថារោងចក្រនឹងមួយធំជាងគេនៅទីក្រុង ។

ធានី ៖ តម្បាញត-១?

ម៉ាន ៖ ចាះ! មានតែមួយនឹងទេ ដែលធំជាងគេ ក្រៅពីនឹងបន្ទាប់បន្សំ ។

ធានី ៖ មានអ្នកណាធំលើបងហ៊ាននឹងទេ?

ម៉ាន ៖ មានៗ គេកាន់ ប៉ុនមិនដឹងជាឈ្មោះអី ខ្ញុំមិនសួរអ្នកចាំដែលទេ ។

ធានី ៖ ស្គាល់គេ ធ្លាប់ឃើញគេមកដែរ?

ម៉ាន ៖ ឃើញតែគណៈរោងចក្រនឹងឯងស្គាល់តែមួយនឹង ហើយប្រធានផ្នែកនានា ស្គាល់តែប៉ុននឹង ។

ធានី ៖ មីងស្គាល់ប្រធានផ្នែកអីខ្លះ?

ម៉ាន ៖ ផ្នែកខាងនេះទៅ ផ្នែកខាងអាគេឲ្យបាយអំបោះនឹងទៅ ហើយជាងគីនឹង សុទ្ធតែផ្នែកៗគេ ។

ធានី ៖ ហើយមេរបស់មីងអ្នកណាគេដែរ ប្រធានរបស់មីង ប្រធានផ្នែករបស់មីង?

ម៉ាន ៖ ប្រធានផ្នែកខ្ញុំឈ្មោះអីទេ ភ្លេចបាត់ហើយច្រើនពេក ឈ្មោះ សន ។

ធានី ៖ សននឹងប្រធានផ្នែករបស់មីង?

ម៉ាន ៖ ចា៎ះ!

ធានី ៖ សននឹងប្រធានផ្នែកអីគេ?

ម៉ាន ៖ ប្រធានផ្នែកតម្បាញម៉ង កន្លែងគីនឹងម៉ង ។

ធានី ៖ ហើយបន្ទាប់មកទៀតម៉េច បន្ទាប់ពីតម្បាញគី មីងធ្វើអីទៀត? មានធ្វើការអីផ្សេងទៀតទេក្រៅពីការងារតម្បាញនឹង?

ម៉ាន ៖ ដល់ឆ្នាំ៧៧ ខែ៧ ខ្ញុំចេញពីនឹងទៀត ។

ធានី ៖ ចាំច្បាស់?

ម៉ាន ៖ ដល់ផ្លាស់ប្តូរយើងដឹង ដល់ដឹងខ្ញុំទៅនៅរោងចក្រផ្សារថ្មី អានឹងរោងចក្រនឹង គេធ្វើកន្លែងសំណង់ឫស្សីកែវ ជិតក្បាលស្ពានបាក់ពីដើម ។ ស្ពានមួយនៅគីឡូលេខ៦កន្លះ គេហៅទៅនឹងហៅឫស្សីកែវ ។

ធានី ៖ មីងធ្វើរោងចក្រអីគេ មិនមែននៅផ្សារថ្មីទេ នៅឫស្សីកែវ?

ម៉ាន ៖ ហ្នឹងហើយ នៅឫស្សីកែវ អានឹងរោងចក្រថ្មី ។

ធានី ៖ ឫស្សីកែវនឹងគេធ្វើអីគេ?

ម៉ាន ៖ កន្លែងនឹងរៀបម៉ាស៊ីនថ្មី ធ្វើរោងចក្រថ្មី ។

ធានី ៖ ធ្វើរោងចក្រអីគេនៅនឹង?

ម៉ាន ៖ រោងចក្រក្រឡឹង ។

ធានី ៖ ជាមួយមីង រីដែរ?

ម៉ាន ៖ អត់ទេ ខុសគ្នា ។

ធានី ៖ រោងចក្រក្រឡឹងអីគេ?

ម៉ាន ៖ ក្រឡឹងបាឡុង ក្រឡឹងអីនឹង ។

ធានី ៖ មីងកាលនឹងធ្វើជាអីគេនៅរោងចក្រនឹង?

ម៉ាន ៖ ខ្ញុំនៅកន្លែងព័ទ្ធដែក ។

ធានី ៖ ធ្វើជាអីគេ ងារ?

ម៉ាន ៖ អានឹងព័ទ្ធដែក កន្លែងរោងចក្រនឹង ព័ទ្ធដែកធ្វើសំណង់នឹង រៀបបានប្រហែលម៉ាស៊ីនក្រឡឹងបាន១០ ដល់៧៩បណ្តោយ ។

ធានី ៖ កាលនឹងមីងមានងារជាប្រធានអីគេអត់?

ម៉ាន ៖ អត់ទេ ប្រធានក្រុម ។

ធានី ៖ ប្រធានក្រុមព័ទ្ធដែកនឹង?

ម៉ាន ៖ ហ្នឹងហើយ ព័ទ្ធដែក ។

ធានី ៖ ចុះប្រធានរោងចក្រនឹងឈ្មោះអីគេ?

ម៉ាន ៖ ឈ្មោះពូ ផាន ។

ធានី ៖ លើពូ ផាននឹង មានអ្នកណាគេ មានស្គាល់ទេ?

ម៉ាន ៖ មានដល់ក្រសួងធំៗខ្ញុំអត់ស្គាល់ទេ ។

ធានី ៖ ចុះការហូបចុកម៉េចដែរ ការរស់នៅ?

ម៉ាន ៖ ការហូបចុកដូចជាមិននេះទេ មួយថ្ងៃ៣ដង អត់មានថាខ្វះអីផង អត់ដឹងថាខ្វះ យើងដឹងតែពីហូបស្លៀកពាក់អីគ្រប់គ្រាន់ អត់ដឹងថាខ្វះអី មិនដឹងថាខ្វះអី ។

ធានី ៖ ម៉េចទៀត?

ម៉ាន ៖ នៅក្នុងរោងចក្រដូចយើងធម្មតានៅជាមួយម៉ែឪ ដូចជាមិនមានលំបាក ។

ធានី ៖ ក្រៅពីការងាររោងចក្រ មានធ្វើអីទៀតទេ?

ម៉ាន ៖ អត់មានធ្វើអីទៀតទេ ។

ធានី ៖ ដែលធ្លាប់បរិច្ចាគឈាមអីទេ?

ម៉ាន ៖ អត់ ។

ធានី ៖ ធ្លាប់មាននៅរោងចក្រគេហៅ?

ម៉ាន ៖ មានៗ កាលនៅរោងចក្រគ-១នោះ មានគេទៅពិនិត្យឈាម បូមឈាម ហើយខ្ញុំខ្លាចពេលកខ្ញុំលេបអាក្រដាស់ទឹក ក្រដាស់ដក់ ។ ដល់ពេលលេបក្រដាស់ដក់អស់២ពុម្ពវា ស្រាប់គេយកទៅឆ្លុះទៅឃើញក្រាលពេញក្រពះ គេអត់ហ៊ានបូមឈាមខ្ញុំទេ ។

ធានី ៖ ម៉េចទៀត?

ម៉ាន ៖ ហើយអីចឹងទៅយើងមកផ្ទះវិញ មកធ្វើការងារវិញទៅ ។

ធានី ៖ ចុះមីងលេបចូលទៅពោះមីងអត់អីទេ?

ម៉ាន ៖ មានអីអាក្រដាសស្តើងៗ ។

ធានី ៖ មុនគេបូមឈាមគេឆ្លុះមើលទៀត?

ម៉ាន ៖ ឆ្លុះមើលពេញក្រពះរូបរាងកាយយើងកើតមានមេរោគក្រាលអី ។ ចុះយើងយកឈាមនឹងទៅប្រើប្រាស់ជំនួយ កាលនឹងថាជំនួយកង៍ទ័ព ។

ធានី ៖ អ្នកណាគេមកប្រាប់នឹង?

ម៉ាន ៖ នៅនឹងកន្លែងប្រធានរោងចក្រនឹង ។

ធានី ៖ ប្រធានរោងចក្រនឹងអ្នកនិយាយ?

ម៉ាន ៖ ចា៎ះ! ឲ្យទៅប្ងមឈាម ខ្ញុំឃើញគេប្ងមឈាមសារមុនដូចរលេះរលះនៅក្នុងរោងចក្រតម្បាញ ត-១នឹង គេអត់មានដូចកន្លែងថ្មីទេ ។

ធានី ៖ អត់ម៉េច?

ម៉ាន ៖ អានឹងហូបបបរលាយពោតលាយអី ។

ធានី ៖ ហើយប្ងមឈាមទៀត?

ម៉ាន ៖ ចា៎ះ! ប្ងមឈាមទៀត សំប្បើមណាស់ ។

ធានី ៖ ប្ងមឈាមនឹងគេស្ម័គ្រចិត្ត ឬក៏ម៉េច?

ម៉ាន ៖ គេចុចឈ្មោះយើងទៅប្ងមម៉ង ។

ធានី ៖ មិនមែនយើងចង់ទេ?

ម៉ាន ៖ អូ! អត់ចង់ទេ លោកអើយ ។ ចង់អីបើមកវិញឃើញគេឡើងធីធះ ឡើងក្តៅដូចឡើងចង់ដាច់ខ្យល់ ។

ធានី ៖ ហើយដល់អីចឹង មានគេជួយ?

ម៉ាន ៖ មិនដឹងជួយអីប្អូន គ្រាន់គ្នាឯងសុំកន្លែងសេដ្ឋកិច្ចគេនឹង អាកន្លែងផ្ទះបាយគេនឹងគេហៅសេដ្ឋកិច្ច សុំកន្លែងនឹងទឹកស្ករ ទឹកអីឲ្យហូបប៉ុននឹងឯង ។

ធានី ៖ ចុះគាត់នឹងម៉េចទៅ គាត់លែងវិញ?

ម៉ាន ៖ ចេះធ្វើការទាំងឈឺ ទាំងត្រដាបត្រដួស ហើយមិនដឹងម៉េចទេ កន្លែងលំបាក ។

ធានី ៖ ចុងក្រោយម៉េចទៅ គាត់ដែលប្ងមឈាមនឹង?

ម៉ាន ៖ អត់អីទេ លែងអីគ្រប់គ្នា ។

ធានី ៖ ប៉ុន្តែដឹបូងរហេរហាស់ទាំងអស់គ្នា?

ម៉ាន ៖ រហេរហាស់ទាំងអស់គ្នា ។

ធានី ៖ ច្រើននាក់ទេ ដែលប្ងមនឹង?

ម៉ាន ៖ ប្ងមប្រហែល១០នាក់ដឹង អានឹងប្ងមលើកទី១ ប្ងមលើកទី២ ១៥នាក់ៗវាងតែខ្ញុំមួយ ។

ធានី ៖ កុំអីត្រូវនឹងគេដែរ គេចុចឈ្មោះដែរ?

ម៉ាន ៖ ចុចឈ្មោះទៅ ដូចថាគេឆ្ងះនឹង ដូចយើងទៅអង្គុយលើតុ យើងទៅកន្លែងអង្គុយទល់មុខគ្នា ឃើញទាំងអស់គ្នា យើងក៏ឃើញ គេក៏ឃើញ មិនដឹងស្តាប់អី ។

ធានី ៖ មីងមើលឃើញដែរ?

ម៉ាន ៖ ចា៎ះ! ឃើញខ្លួនឯង ក្រដាស់ឡើងពេញនឹងរីក យើងលេបប្រហែលជា១៥នាទីពិនិត្យហើយមួយ ។

ធានី ៖ កាលនឹងមឹងភ័យខ្លាំងបានលេប?

ម៉ាន ៖ ភ័យខ្លាំង ភ័យម្យ៉ាង ភ័យយើង ។

ធានី ៖ គិតម៉េចបានលេបក្រដាសចូលពោះ?

ម៉ាន ៖ និយាយមានរឿងចេះ កាលពុកខ្ញុំធ្វើទាហានកាលជំនាន់គាត់ ថាឲ្យស្មុគ្រចិត្តចុចដូចគ្នា គាត់ខ្លាចដូចខ្ញុំ គាត់ថាគាត់លេបក្រដាស់នឹងទៅ ខ្ញុំចាំអានឹងខ្ញុំលេបសាកមើល លេបទាំងភ័យ គេថាវៃចោល ។

ធានី ៖ យើងអត់ព្រម?

ម៉ាន ៖ អឺ! បើយើងធ្វើល្បិចអីចឹង តែគេដឹងរឿងយើងទាន់ គេវៃយើងចោល ។

ធានី ៖ យើងលេបក្រដាសចូលពោះ គេថាម៉េច គេដឹងថាអានឹងក្រដាសទេ?

ម៉ាន ៖ គេអត់ដឹង១ដែរ ។

ធានី ៖ គេថាស្អីអីគេ?

ម៉ាន ៖ អត់ដឹង មិនដឹងស្អី គេឲ្យខ្ញុំដេកពេទ្យប្រហែលជា៣ថ្ងៃដែរ ។

ធានី ៖ ឲ្យមឹងដេកពេទ្យទៀត?

ម៉ាន ៖ ហ្អឹងហើយ ។

ធានី ៖ ដល់ពេលពិនិត្យមើលទៅ ចេញអីទៅ?

ម៉ាន ៖ ដល់នេះទៅអត់មានពិនិត្យទៀតទេ ដេកពេទ្យតែ៣ថ្ងៃនឹង គេបញ្ជូនមករោងចក្រវិញ ។

ធានី ៖ ឲ្យគ្រាន់មឹងឃើញមឹងដាក់ក្រដាសក្នុងពោះទៅចេះតែភ័យ ឲ្យមឹងដេកពេទ្យទៅ ។

ម៉ាន ៖ ហ្អឹងហើយ ។

ធានី ៖ ហើយមឹងដេកពេទ្យ គេពិនិត្យជម្ងឺចាក់ថ្នាំឲ្យមឹងអត់?

ម៉ាន ៖ គេចាក់នឹងហើយ ព្យាបាល មិនដឹងព្យាបាលថ្នាំស្អី១ខ្លះ ខ្ញុំមិនដឹងដែរ ចេះព្យាបាលទៅ តែ៣ថ្ងៃចេញមករោងចក្រវិញមក ។

ធានី ៖ មឹងពេលនឹងមឹងអត់ប្រាប់គេណា?

ម៉ាន ៖ ប្រាប់ណាជីវិតណា ទៅប្រាប់អ្នកណាបាន ។

ធានី ៖ គេឲ្យចាក់ថ្នាំចាក់ទៅ?

ម៉ាន ៖ អឺ!

ធានី ៖ ចាក់ថ្នាំអត់អីណាមឹង?

ម៉ាន ៖ អត់មានអីទេ ។

ធានី ៖ ហើយហូបអីម៉េចហូបនៅពេទ្យ?

ម៉ាន ៖ នៅពេទ្យធម្មតា អត់មានបបរអីទេ ហូបបាយ គ្រាន់បាយម៉ាចានៗ ទំរាំយើងមនុស្សស្រី យើងហូបឆ្អែតប៉ុណ្ណោះឯងម៉ាពេល ។

ធានី ៖ កាលមីងនៅពេទ្យនៅណា?

ម៉ាន ៖ គេថាពេទ្យ៧៥ ៗមិនដឹងពេទ្យត្រង់ណា

ធានី ៖ ត្រង់ណាពីរោងចក្រទៅ ឆ្ងាយ?

ម៉ាន ៖ ទៅជិតវត្តភ្នំ មុំនឹង ។

ធានី ៖ កាលនឹងមីងចូលពេទ្យនៅឆ្នាំប៉ុន្មាន?

ម៉ាន ៖ ឆ្នាំ ។

ធានី ៖ ព្រោះកាល៧៦មីងមកនៅតម្បាញ?

ម៉ាន ៖ ដូច៧៦នឹងឯង ។

ធានី ៖ ដើមឆ្នាំចុងឆ្នាំ?

ម៉ាន ៖ ប្រហែលចុងឆ្នាំ ដល់៧៧យើងបែកមកពីនោះ ។

ធានី ៖ ៧៧មីងមកឬស្សីកែវវិញ?

ម៉ាន ៖ ចាំះ! ឬស្សីកែវវិញ ។ បើគ្នាដេកមិនបានផង៣-៤ថ្ងៃ ប្រើគ្នាទៀត ។ ហើយវេណម៉ាយប់ ទល់ភ្លឺវេណម្តង ។

ធានី ៖ មួយយប់ទល់ភ្លឺ អត់ឲ្យគេងទេ?

ម៉ាន ៖ ម៉េចអត់គេងទេ មកដល់គ្រាន់ម៉ាយប់ទល់ភ្លឺមកដល់ពេលកម្មទៀត ។ ហើយហូបបាយចូលផ្លាស់ទៀត គ្មានពេលសម្រាកទេ នៅក្នុងរោងចក្រនោះ ។ បានចេញមកប្រជាជននៅតាមជនបទអី គាត់ថា ពួកអ្នកនៅភ្នំពេញកន្លែងកម្មករនឹង សុទ្ធតែហូតញើស ហូតឈាមគាត់ៗថាយើងក្បត់ យើងស៊ីកម្លាំង ស៊ីញើសឈាមគាត់ ហើយទ្រព្យសម្បត្តិរបស់គាត់នៅទីក្រុងភ្នំពេញ លេបត្របាក់អស់ ។ ការពិតអត់ទេ លេបត្របាក់អីគ្នាហូតបបរចង់ស្លាប់ ហើយប្រើគ្នាមិនដឹងយប់មិនដឹងថ្ងៃ ។ ថ្ងៃគេត្រូវវេណម៉ាអាទិត្យវេណយប់ វេណថ្ងៃ គេបានសម្រាន្តយប់ទៅ យើងយប់នឹងអត់បានសម្រាកទេ ថ្ងៃបានសម្រាកទៅ ។ វេណយប់នោះទល់ម៉ាអាទិត្យនោះបានសម្រាកម្តង ។

ធានី ៖ មីងវេណយប់ វេណថ្ងៃទៀត គេឆ្លាស់គ្នារហូត?

ម៉ាន ៖ ហ្នឹងហើយម៉ាអាទិត្យដល់វេណម្តង ថ្ងៃម្តងយប់ម្តង ។

ធានី ៖ ត្រូវវេណយប់នឹងធ្វើហើយស្អែកឡើងផ្លាស់មកថ្ងៃ ធ្វើថ្ងៃទៀតអត់គេ?

ម៉ាន ៖ អានឹងគេដាក់ម៉ាអាទិត្យម្នាក់ ។

ធានី ៖ មួយអាទិត្យមានម៉ាថ្ងៃ ដែលមិនអត់បានសម្រាកពេញមួយថ្ងៃ ត្រូវធ្វើការតាំងពីព្រឹកទល់យប់ យប់ហើយទល់ភ្លឺ?

ម៉ាន ៖ ម៉ាអាទិត្យនឹងឯង យើងហត់រហូត ។

ធានី ៖ បន្ទាប់មកទៀតម៉េចទៀត ថានៅបុស្សីកែវហើយទៅណា?

ម៉ាន ៖ ដល់បុស្សីកែវមក ដូចថាវាមានសង្គ្រាមសារថ្មី ថាយួនៗក៏នាំគ្នារត់ចូលព្រៃលិចអស់មក ។

ធានី ៖ ខាងណាព្រៃលិចនឹង?

ម៉ាន ៖ មកខាងនឹង មកខាងយើងនៅរាល់ថ្ងៃនឹង ។

ធានី ៖ ជំបូងរត់ពីណាទៅបានដល់នឹង?

ម៉ាន ៖ រត់មកតាមផ្លូវបែកចាន ។

ធានី ៖ ចេញពីភ្នំពេញបែកចានទៅណាវិញ?

ម៉ាន ៖ ដឹងមកខាងណាវិញទេ ដឹងដើងត្បូងលិចកើតទេ ចេះមកតាមគេ ។

ធានី ៖ តាមអ្នកណាគេមកតាមអ្នកណាគេដឹកនាំមក?

ម៉ាន ៖ ថាដឹកនាំមកតាមគណៈរោងចក្រនឹង ។

ធានី ៖ គណៈរោងចក្រឈ្មោះ ហ៊ាននឹង?

ម៉ាន ៖ អត់ទេ ឈ្មោះ ពូ ផាន ។ ដល់ពេលអីចឹងនៅនឹងគាត់បានម៉ាឆ្នាំ មិនសូវស្គាល់ច្បាស់លាស់ទេ យើងរញ៉េរញ៉ៃពេកទៅភ្លេចអស់អ្នកនៅជាមួយ ។ ដល់អីចឹងចេះថាយួនៗ ចេះក្តុងក្តាំងតាមក្រោយ យើងចេះទៅៗ នាំគ្នារុញគ្នាទៅ តាំងពីប្រជាជន កសិករ តាំងពីកន្លែងប្រជាជននៅតាមជនបទទៅ ចេះមានម៉ូតូ មានឡាន ខ្លះទៅមានរទេះគោ ចេះទៅនាំគ្នាមករង្គើលព្រៃ ។

ធានី ៖ មកឆ្លងព្រៃអីខ្លះទៅ?

ម៉ាន ៖ មិនដឹងព្រៃអីៗទេ មិនចាំទេ ។

ធានី ៖ ពិបាកទេ ឃើញទិដ្ឋភាពអីខ្លះ?

ម៉ាន ៖ ទិដ្ឋភាពនោះ វាមានគ្រប់បែបគ្រប់យ៉ាងអស់ហើយ ។

ធានី ៖ និយាយប្រាប់មើល ឃើញទិដ្ឋភាពម៉េចខ្លះពេលមីងមកដល់ព្រៃ?

ម៉ាន ៖ មកដល់នឹងដើរជួនណាឃើញរណ្តៅ គេវៃមនុស្សវៃអីចោលគក់ស្អុតណាស់ ប៉ុនមិនដឹងអ្នកណាជាអ្នកណៃទេ វៃចោល ។ ដើរៗប៉ះឃើញគេកាប់គ្នាម៉ាកំណាត់ មួល-ក សុទ្ធតែស្រីៗដាក់បង្គងលើភ្លឺស្រែ ប៉ុនមិនដឹងអ្នកណា ។ វាដូចថាអីចឹងវាគក់ស្អុតដែរ យើងដើរជួបប្រទះនឹង

ទាំងខ្លាចខ្លួនឯង ទាំងខ្លាចខ្មោច ។ ដើរតាមព្រៃមកឃើញសុទ្ធតែគំនរខ្មោច គិតទៅ នៅទីក្រុងភ្នំពេញមិនដឹងរឿងអីទេ ដល់មកដល់ជនបទនេះចេះបានដឹងរឿង ថារឿងកាប់សម្លាប់វាមានពិតមែន ។

ធានី ៖ មីងបានដឹងរឿងនឹង ពេលដែលមីងរត់ភៀសខ្លួនទេ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ដែលថាឮគេនិយាយថាកាប់សម្លាប់ អត់ជឿគេទេ?

ម៉ាន ៖ ចា៎ះ! អត់ដឹងរឿងទេ ។

ធានី ៖ ដល់ពេលមកឃើញគេកាប់សម្លាប់អីចឹងម៉េចទៅមីង មីងឃើញផ្ទាល់ភ្នែកមានអារម្មណ៍ម៉េច?

ម៉ាន ៖ ឃើញតែរណ្ដៅគេនឹង គ្មានឃើញអ្នកណា យកសម្លាប់អ្នកណាទេ យើងដើរទៅដូចថា ។

ធានី ៖ ឃើញសាកសព?

ម៉ាន ៖ ឃើញសាកសព គំនរសាកសព ឃើញតាមគៀនដំបូង គៀរភ្លឺស្រែ ឃើញតាមរណ្ដៅមានដាប្រចាំទាល់តែចូលមកព្រៃធំនេះ ។ មកតាំងកាលនឹងចូលតាមម៉ក់ហឺនមកក្នុងនឹង ។

ធានី ៖ ពេលមីងចូលមកម៉ក់ហឺន មីងមានឃើញទំនប់មួយនៅម៉ក់ហឺន?

ម៉ាន ៖ ទំនប់នឹង មានឃើញដែរ ទំនប់នឹង មកដល់តាគង់ មកអូរសណ្ដាយអីនឹង ម្ដុំនឹង ។

ធានី ៖ ម្ដុំនឹងឃើញមានទំនប់ធំមួយ?

ម៉ាន ៖ ទំនប់ៗ គេហៅទំនប់មិនដើរចំទេ ។

ធានី ៖ អត់ដើរចំទេ?

ម៉ាន ៖ អត់ដើរអត់ចំទេ កន្លែងទំនប់នឹង ។

ធានី ៖ នៅម្ដុំនឹងពេលមីងមកដំបូង មីងមើលទៅឃើញមានប្រជាជនរស់នៅទេ មានផ្ទះ មានសម្បែងអីទេ?

ម៉ាន ៖ មានកន្លែងតាគង់ ។

ធានី ៖ នៅភូមិតាគង់នឹង មានប្រជាជន មានមនុស្សរស់នៅ?

ម៉ាន ៖ ចា៎ះ! មានៗឃើញវត្តឃើញអី ។

ធានី ៖ មានវត្តទៀត?

ម៉ាន ៖ ចា៎ះ! មានកាលនឹង ប៉ុនវត្តចាស់ គ្មានឃើញលោកទេ ។

ធានី ៖ មីងដឹងថាកន្លែងតាគង់នឹងពីមុនគេហៅភូមិឃុំអីទេ ពីមុនគេហៅតាគង់?

ម៉ាន ៖ ទេ! មិនដឹងថាអីទេ ប៉ុនគេគ្រាន់ឮគេថាកន្លែងតាគង់ ។

ធានី ៖ តាគង់នឹងមិនមែនឈ្មោះឥឡូវទេ ឈ្មោះពីមុនហើយ?

ម៉ាន ៖ ឈ្មោះពីមុនមិនដឹង ព្រោះអីមកដល់គេថាភូមិកន្លែងនេះមានវត្តមានអី វត្តអត់ទាន់រុះរើស ថាភូមិតាគង់ គេនិយាយតាគង់ៗ ។

ធានី ៖ គេហៅភូមិតាគង់?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ហើយម៉េចទៀតទៅ អត់ឃើញមនុស្សទេ ឃើញតែវត្តឃើញតែអី?

ម៉ាន ៖ មនុស្សវាមានច្រើនណាស់ មនុស្សឡើងរន្តើលព្រៃ មកដូចទឹកបាក់ទំនប់ មកពីនឹងមករហូតរត់តគ្នា ពីភូមិ ពីកសិករទៅណាទៅណែមកទាំងអស់ កងកុមារទាំងអីនឹង ។ មានថ្ងៃមួយនោះឡើងដើងភ្នំណាទេ ចាំមិនបានទេ ដើងភ្នំតូចៗ ។ កុមារកំពុងហូបបាយ គួរឲ្យតក់ស្លុតកន្លែងនឹងហូបបាយៗមិនដឹងអ្នកណាគេបោកគ្រាប់បែកដឹងមកសាប់កុមារឡើងរាល ។

ធានី ៖ សុទ្ធតែកូនក្មេងទាំងអស់?

ម៉ាន ៖ កូនក្មេងតូចៗអាយុ១០ឆ្នាំ ៧-៨ឆ្នាំ ដែលទើបកុមារ ។ កាលមុនយើងមិនកុមារហើយ នឹងមែឪនៅដោយខ្លួន ។ ដល់អីចឹងទៅ វាមានឃើញអានឹងដែលផ្ទាល់ភ្នែក ។

ធានី ៖ អត់ដឹងខាងណា?

ម៉ាន ៖ ហ្នឹងហើយអត់ដឹងខាងណាទេ ចូលក្តុងក្តាំង ស្រាប់ទៅមើលគេ កូនក្មេងត្រូវរបួសផងអីផង ។

ធានី ៖ មានស្លាប់ច្រើនទេ?

ម៉ាន ៖ ស្លាប់ប្អូន កំពុងហូបបាយបោះអាកន្លែងនឹងម៉ង មិនដឹងបោះធ្វើស្អីមានគ្រាប់បែកគេយក ។

ធានី ៖ មានដឹងខាងណាអ្នកបោះ?

ម៉ាន ៖ អត់ដឹងរឿង យើងដល់អីចឹងយើងភ័យដែរ យើងមកវិញ នាំគ្នាទៅមើល២-៣នាក់មានហេតុការណ៍ទៅរត់ទៅឃើញឈាមរលេបរលាបនឹង យើងអ្នកដំណើរដល់អ្នកដំណើរដូចគ្នាមិនដឹងជួយគ្នាម៉េច យកតែម៉ារួចខ្លួន ។

ធានី ៖ អត់ដឹងខាងណាអ្នកបោះដាក់ឲ្យ?

ម៉ាន ៖ អត់ដឹង ។

ធានី ៖ គ្នាយើង ឬគ្នាគេ?

ម៉ាន ៖ មិនដឹងគ្នាណា មនុស្សៗគ្រប់ក្រសួងគ្រប់ស្ថាប័នទាំងអស់ ដើរទៅណាខ្ទេចព្រៃត្រង់នឹង ។ អាណិតណាស់កូនគេកូនយើងប្អូនគេប្អូនយើង នឹកឃើញថាកុមារតូចៗ ហើយនឹងឪម៉ែកុមារតូចៗយំទ្រហឹង មិនដឹងស្រវាណាទុកណា បែបស្លាប់ក្នុងព្រៃទាំងអស់ត្រូវល្ហមៗក៏ស្លាប់មិនដឹងយកទៅណារួច ។ បើម៉ែកុមារតែ២នាក់ ហើយគេយកទៅណា កាលមិនទាន់គ្រោះថ្នាក់ទៅចេះ

តែបណ្ដើរ ដើរមកអីចឹងមានស្នឹមកៗម៉ាខ្លួន ស្ពាយអង្ករកូនក្មេងតូចៗស្ពាយបាន២-៣កំប៉ុងនឹង នាំគ្នាស្ពាយគ្នាមកអីចឹងរហូត ។

ធានី ៖ កុមារនឹងស្លាប់ទាំងអស់ មានរស់មួយ?

ម៉ាន ៖ មិនដឹងយ៉ាងម៉េច ប៉ុនស្លាប់ភាគច្រើន របួសស្លាប់ មិនដឹងជាអ្នកណាលោកណាអាណាគេអ្នកធ្វើម៉ង ។ ចិត្តដាច់ណាស់ គ្នាហូបបាយ អាណាគេជាអ្នកធ្វើ ចិត្តដាច់ គ្នាកំពុងហូបបាយ ។ ទោះអត់ឃ្លានស្លាប់ក្នុងព្រៃវាគ្រាន់មើល ។

ធានី ៖ ហើយម៉េចទៀត ពេលដើរទៅមុខ?

ម៉ាន ៖ ដើរមកមុខជួបតែអត់នឹងឯង ដើរមកចូលក្នុងព្រៃនេះវាអត់ខ្លាំងណាស់ ដាច់ស្បៀងអាហារនឹងនាំគ្នាកាន់សុទ្ធតែឈើច្រត់នោះ ហើយស្លាប់ក៏ស្លាប់ច្រើន ។ ខ្ញុំម៉ាក្រុម១២នាក់ នៅសល់តែខ្ញុំមួយទេ ។

ធានី ៖ ១២នាក់?

ម៉ាន ៖ ១២នាក់ ។

ធានី ៖ ដោយសារអី?

ម៉ាន ៖ អត់ ។

ធានី ៖ អត់ហូប?

ម៉ាន ៖ អត់ហូបតែម្ដងដាច់បាយជិតកន្លះខែ យើងមានណាក៏អត់ ខ្ញុំចេះដើរស៊ីស្លឹកឈើ ស្លឹកព្រៃតែពាស ។ ៧៩ វេទនាមែនទែន និយាយពីថ្ងៃត្រង់បើថាមេឃស្រទុំចេះងងឹតដូចយប់ ។

ធានី ៖ ម៉េចអីចឹង?

ម៉ាន ៖ ក្នុងព្រៃងងឹតសូន្យ ត្រង់នឹងងងឹត អស់នឹង ។

ធានី ៖ ព្រៃក្រាស់?

ម៉ាន ៖ ក្រាស់ងងឹតសូន្យ ចេះម៉ោង៣ឡើងមាន់ព្រៃឡើងរងាវទ្រហឹង ។

ធានី ៖ មានមាន់ព្រៃរងាវទៀត?

ម៉ាន ៖ ខ្វះអីសត្វជ្រូកព្រៃ សត្វអីមិនខ្វះទេ មិនជួបតែខ្លានិងដំរីទេ ក្រៅពីនឹងសត្វមិនខ្វះ ។

ធានី ៖ ជួបទាំងអស់គ្នាន់ ប្រើសអី?

ម៉ាន ៖ អូ! ច្រើនណាស់ ឥឡូវនេះងាប់អស់ហើយ នៅសល់តែដីទទេរ ខ្ញុំមិនស្មានណាថាដីអស់នឹងបានស្រឡះមានមនុស្សនៅដល់ម្លឹងរាល់ថ្ងៃ ។

ធានី ៖ កាលមុនមីងអត់នឹកស្មានដល់ ព្រោះវាព្រៃក្រាសពេក?

ម៉ាន ៖ ព្រៃក្រាស់ណាស់ ហើយយើងមកពីនោះមានកាំបិត មានពូថៅអី មានដៃទទេរ ជាន់ៗព្រៃកន្លែងដេក វេទនាទឹកភ្លៀងមកមិនចេះតូចនាំគ្នាជ្រក ។ រងាទោះបីមិនភ្លៀងក៏រងាៗនឹងអត់នឹងម៉ង ដល់ពេលយើងអត់ ហើយយើងអស់កម្លាំង យើងរងារហូតនៅក្នុងក្រោមម្លប់ផងរងារហូត ។ គិតទៅមិនថាអ្នកណា មិនថាស្រី មិនថាប្រុស ដូចគ្នាទាំងអស់ និយាយពីដើរកាន់ឈើច្រត់ ផ្លូវប៉ុនរនេះដើរបុកគ្នា វាទ្រេតទ្រោឌដូចយើងស្រវឹង ដើរទៅមើលមុខគ្នាស្អប់ម៉ង ។ ពេលនឹងស្អប់គ្នាទៅវិញទៅមក ។

ធានី ៖ ម៉េចអីចឹង?

ម៉ាន ៖ វាមើលទៅមុខដូចជាខ្មោចរៀងខ្លួនហើយ ដើរទង្គិចគ្នាផ្លូវប៉ុនផ្លូវដើរទៅប៉ះដីរអិល វាទ្រេតទៅរកគ្នា អាមួយជេរអាមួយមិនថាប្រុស មិនថាស្រីជេរជុតគ្នា ។ គិតទៅមនុស្សយើងខឹងគ្នាអីចឹងតើ ចង់កើតជាខ្មោចហើយមិនបានទេ ខឹងគ្នាទៀត ។

ធានី ៖ ហើយធ្វើម៉េចបានដើរដល់នេះ?

ម៉ាន ៖ ចេះតែរុញគ្នាដើរៗគេថាយួនមកដល់ត្រង់នេះ អត់ឃើញយួនទេមិនដឹងឯណា គេថាយួនមកដល់ត្រង់នេះ រត់ប្រុយ ។

ធានី ៖ ហត់អស់កម្លាំងហើយរត់ទៀត?

ម៉ាន ៖ អស់ចេះដើរ ចេះតែរត់ហើយ ខ្លះហើមជើងទៅ ខ្លះគ្រុន ចុះមូសខាំតាមព្រៃគ្រុនចាញ់ ញាក់ញ័រពេញនឹងទៅ ។

ធានី ៖ មានថ្នាំមានអីទេ?

ម៉ាន ៖ មានថ្នាំមកពីណា ។ យូរៗគេបើកអង្ករឲ្យ១០កំប៉ុង ហើយមិនដឹងជាថ្ងៃណាគេផ្តល់អង្ករឲ្យទៀតមកនេះបបរម៉ាឆ្នាំ គាត់ដាក់តែ២ស្លាប់ព្រាអង្ករនោះ ២ស្លាព្រាបាយគត់ដាក់ក្នុងទឹកនឹង មិនដឹងណាណៃចេះ ស្ងោរអាស្លឹកឈើណាស្គាល់ៗបេះដាក់ៗហូប ។ ទម្រាំបានជីវិតមកដល់សព្វថ្ងៃនេះ អ្នកនៅកន្លែងនេះទាំងអស់គ្នាដែលនៅតាមជាយដែននេះ យ៉ាប់ដូចគ្នាគ្មានអ្នកណាបានបាយហូបស្រួលទេ ដល់ចូលដីថៃហើយបានបាយហូប ។

ធានី ៖ នៅចន្លោះពី៧៩ដល់៨៥នឹង គឺអត់ទាន់បានអីហូបស្រួលបួលទេ នៅពិបាកនៅគ្រុនចាញ់?

ម៉ាន ៖ នៅ មើលដល់ឆ្នាំ៨០ចូលជំរុំខ្លះ មានគេទាក់ទងខាងរត់ខាងនេះនឹង ខាងអង្គការនឹង គេទាក់ទងខាងថៃបាន ។

ធានី ៖ អង្គការណា?

ម៉ាន ៖ មិនដឹងអង្គការណាៗ គេហៅអង្គការ ។

ធានី ៖ ជំរុំអីគេនឹង?

ម៉ាន ៖ ជំរុំមានជំរុំច្រើន មានជំរុំតាឌុំក មានជំរុំស្រះកែវ ជំរុំអានឹងជំរុំផ្នែកខាងនោះអត់គិតទេ មាន ៧ជំរុំ ។

ធានី ៖ មានតាឌុំក ស្រះកែវ?

ម៉ាន ៖ ចាំះ! ស្រះកែវទី១ ស្រះកែវទី២អាចទៅនឹង ។

ធានី ៖ ចុះជំរុំមួយទៀត ខាវអ៊ីដាងនៅខាងណា?

ម៉ាន ៖ កន្លែងខាវអ៊ីដាងនឹងខាងគេកាន់ខាងប៉ុរ៉ា ។

ធានី ៖ មានគេផ្សេងទៀត?

ម៉ាន ៖ ចាំះ! មិនមែនខ្មែរក្រហម មានប៉ុរ៉ាម៉ាផ្នែកទៀត ។

ធានី ៖ ចុះយើងចូលខាងណា ខ្មែរក្រហមយើងនៅខាងតាឌុំកហើយនឹងនេះឯង?

ម៉ាន ៖ ចាំះ! តាឌុំក ហើយនឹងស្រះកែវទី១ ទី២នឹងឯង ។

ធានី ៖ ចុះសាយធូ សាយអេចនៅខាងណា?

ម៉ាន ៖ ខាងជំរុំប៉ុរ៉ាខាងនឹង ។

ធានី ៖ ហើយប៉ុរ៉ាខាងណា?

ម៉ាន ៖ ប៉ុរ៉ាដូចខាងណាទេ ដូចខាងខ្មែរក្រហមដែរនឹង ប្រឆាំងខាងរដ្ឋាភិបាលដែរ ។

ធានី ៖ ម៉េចគេដាក់ប៉ុរ៉ា?

ម៉ាន ៖ ហ្នឹងហើយខាងយួនដែរ ប្រឆាំងខាងយួនមិនមែនប្រឆាំងខាងខ្មែរយើងទេ ។

ធានី ៖ មិនមែនទាហានខ្មែរក្រហមយើងនៅទេ?

ម៉ាន ៖ អត់ទេ ប៉ុរ៉ានឹងដោយឡែកពីគ្នាទៀត ។

ធានី ៖ ចុះសាយធូ សាយអេច?

ម៉ាន ៖ សាយអេច សាយធូនោះ អានោះជំរុំប៉ុរ៉ានៅ ប៉ុរ៉ានិងខ្មែរ ។

ធានី ៖ ចុះជំរុំទី៧?

ម៉ាន ៖ ហ្នឹងជំរុំ៧អីនឹង ប៉ុរ៉ាដែរ ។ ពួកនឹងអត់ត្រូវគ្នាជាមួយថា យើងខាងនេះនិយាយថាខ្មែរក្រហម ម៉េចទេ ខាងក្នុងថាខ្មែរក្រហម ចេះហៅខ្មែរក្រហមគេ ។

ធានី ៖ ចុះខាងភ្នំព្រឹក ខាងអីគេ ជំរុំអីគេ?

ម៉ាន ៖ ហ្នឹងខ្មែរក្រហមដូចគ្នា ។

ធានី ៖ ហ្នឹងគេហៅជំរុំអីគេ?

ម៉ាន ៖ នេះខ្មែរក្រហមដូចគ្នា ។

ធានី ៖ តែជំរុំនៅថៃនឹង គេហៅជំរុំអីគេ?

ម៉ាន ៖ ហ្នឹងគេនៅនឹងទាំងអស់នឹងកន្លែង ។

ធានី ៖ ជំរុំស្រះកែវ គាត់ផ្ទុកអីនឹង?

ម៉ាន ៖ ហ្នឹងហើយ ។

ធានី ៖ យើងនៅជុំគ្នាទាំងអស់?

ម៉ាន ៖ ហ្នឹងហើយ នៅនឹងទាំងអស់ ។

ធានី ៖ ស្រះកែវនឹងនៅដីថៃ?

ម៉ាន ៖ នៅដីថៃ ។

ធានី ៖ ចុះដល់ពេលណា បន្ទាប់មកទៀតមីងរត់ទៅនៅជំរុំសិន ។ បន្ទាប់មកពីស្រះកែវវិញទៅណាទៀត?

ម៉ាន ៖ មកពីស្រះកែវមានដីរហូត ។

ធានី ៖ ស្រះកែវនៅឆ្នាំប៉ុន្មាន?

ម៉ាន ៖ ឆ្នាំ៨០ ។

ធានី ៖ ឆ្នាំ៨០នៅស្រះកែវ?

ម៉ាន ៖ ចា៎ះ! មានប្ដីនៅស្រះកែវ ។

ធានី ៖ គ្រួសារមីងឈ្មោះអីគេ?

ម៉ាន ៖ ឈ្មោះ យឿង ។

ធានី ៖ អីគេយឿង?

ម៉ាន ៖ ធូ យឿង ។

ធានី ៖ គាត់នឹងអ្នកដូចមីងដែរ ឬក៏មកពីណា?

ម៉ាន ៖ មកពីព្រៃវែង ស្រុកជិតគ្នាកើតជាមួយគ្នា ។

ធានី ៖ គាត់នឹងខ្មែរក្រហមដែរ?

ម៉ាន ៖ ខ្មែរក្រហមដូចគ្នា ។

ធានី ៖ រៀបគ្រួសារនៅស្រះកែវ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ហើយបន្ទាប់មកទៀតធ្វើអីទៀត?

ម៉ាន ៖ បន្ទាប់មកទៀត មកនឹងវិញ ។

ធានី ៖ ត្រឡប់មកនេះវិញ?

ម៉ាន ៖ អឺ! វិលៗមកនឹងវិញ ។

ធានី ៖ មកធ្វើអី?

ម៉ាន ៖ មកនឹងប្ដីខ្ញុំធ្វើទាហាន យើងធ្វើប្រជាជនធម្មតា ។

ធានី ៖ ហើយមីងលែងធ្វើទាហានហើយ?

ម៉ាន ៖ លែងហើយតាំងពីចូលទីក្រុងនឹង ។

ធានី ៖ ចូលទីក្រុងអី?

ម៉ាន ៖ ចូលទីក្រុងភ្នំពេញរហូតមក មានធ្វើអីទៀត ។

ធានី ៖ ឈប់ធ្វើទាហាន?

ម៉ាន ៖ អឺ! ឈប់រហូត ។

ធានី ៖ ហើយមីងនៅផ្ទះ ហើយគ្រួសារធ្វើទាហាន?

ម៉ាន ៖ ចាំះ!

ធានី ៖ ហើយគាត់ធ្វើទាហាននឹងនៅណាវិញ?

ម៉ាន ៖ នៅក្នុងម៉ាឡៃនឹង ។

ធានី ៖ ហើយមីងផ្ទះនៅម៉ាឡៃ?

ម៉ាន ៖ នៅនឹងដែរ ។

ធានី ៖ កាលនឹងនៅដំបូងម៉េចដែរ មានអីជ្រក?

ម៉ាន ៖ មានអីប្អូន មកពីស្រះកែវវិញ គេមកពីនោះ គេបើកចក បើកស្រូវពូជ បើកមកដែលយើងទៅៗ ។

ធានី ៖ មីងមកពីស្រះកែវឆ្នាំប៉ុន្មាន?

ម៉ាន ៖ ឆ្នាំដែលមីងមានប្ដីនឹង ។

ធានី ៖ ឆ្នាំ៨០ដែរ?

ម៉ាន ៖ ហ្នឹងហើយ គ្រាន់ចុងឆ្នាំ ដើមឆ្នាំ ។

ធានី ៖ ចុងឆ្នាំ៨០នឹង គ្រួសារត្រឡប់មកធ្វើទាហាននៅម៉ាឡៃ?

ម៉ាន ៖ ហ្នឹងហើយ ។

ធានី ៖ ហើយមីងកាប់ឆ្ការក្បែរផ្ទះនឹងទៅ?

ម៉ាន ៖ ហ្នឹងហើយ ទាំងគេទាំងយើងមកទាំងអស់គ្នានឹង ក៏កាប់គាស់រស់រាននេះទៅតិចតួចទៅ ចេះធ្វើទៅ ។ ប៉ុនវាមិនអត់ទេ គេបើកឲ្យ ដល់នឹងសំបូរវិញហើយ ។

ធានី ៖ សំបូរម៉េច?

ម៉ាន ៖ សំបូរដូចថាតាំងពីចុងសក់ ដល់ចុងជើង វាសំបូរសំលៀកបំពាក់ សំបូរហូបចុក អត់មានបញ្ហាអីទេ ទាល់តែយើងមិនមានទាន់ប្រើលុយ ។

ធានី ៖ ម៉េចទៀតមីង?

ម៉ាន ៖ រស់នៅនឹងទៅលិចអណ្ដែតៗ តិចទៅខាងក្នុងវិញចូលក្នុងដីថៃទៀត ។

ធានី ៖ ចូលពេលណា?

ម៉ាន ៖ ចូលមិនដឹងឆ្នាំប៉ុន្មានទេ ខ្ញុំមានកូនមួយ មីបង ។

ធានី ៖ គាត់កើតឆ្នាំប៉ុន្មាន?

ម៉ាន ៖ កើតឆ្នាំកុរ អាយុ២០ជាង បែប២០ជាង បែបជាជំណាលប្អូនឯង ។

ធានី ៖ ៨៤ ៨៥ ៨៣ ៨៤?

ម៉ាន ៖ ៨៣ ។

ធានី ៖ ៨៣រត់ចូលម្ដងទៀត?

ម៉ាន ៖ អឺ!

ធានី ៖ ចុះទៅកន្លែងណាវិញ ម្ដងនឹង?

ម៉ាន ៖ កន្លែងជំរុំ៨៥ គេហៅ៨៥ ។

ធានី ៖ គាត់កើត៨៣ម៉េចជំរុំនឹងគេដាក់៨៥?

ម៉ាន ៖ ជំរុំគេដាក់ឈ្មោះអីចឹង ។

ធានី ៖ កូនរបស់មីងបានម៉ាឆ្នាំហើយ?

ម៉ាន ៖ រត់ ទៅចូល ។

ធានី ៖ កូនបានម៉ាឆ្នាំជាងហើយ បានរត់?

ម៉ាន ៖ ហ្នឹងហើយ រត់ទៅចូលនៅជំរុំ៨៥នឹងដែរ ។

ធានី ៖ ជំរុំនឹងកើតឆ្នាំ៨៥?

ម៉ាន ៖ អឺ!

ធានី ៖ នៅបានប៉ុន្មានបានមីងមកវិញម្ដងទៀត?

ម៉ាន ៖ មិនដឹងប៉ុន្មានទេ ចេញមកមិនដឹងឆ្នាំប៉ុន្មានទេ ភ្លេចហើយ ។

ធានី ៖ មីងចេញមកម្ដងទៀត?

ម៉ាន ៖ ចេញ ។

ធានី ៖ ចុះគ្រួសារមីងធ្វើទាហានទៀតអត់?

ម៉ាន ៖ ធ្វើ មីងនៅនឹង ប្ដីមីងស្លាប់ ។

ធានី ៖ គ្រួសារមីងស្លាប់ឆ្នាំប៉ុន្មាន?

ម៉ាន ៖ ៨០ប៉ុន្មានទេ ៨៦ ៨៧ ។

ធានី ៖ ច្បាស់ទេ?

ម៉ាន ៖ អត់សូវច្បាស់ទេ ។

ធានី ៖ កាលនឹងកូនមីងអាយុបានប៉ុន្មានឆ្នាំ?

ម៉ាន ៖ កូនមីងក្រោយអាយុបានម៉ាខួប គិតទៅ៤ឆ្នាំ២ មីប្អូននោះកើតឆ្នាំខាល ។

ធានី ៖ ៨៦?

ម៉ាន ៖ ចា៎ះ!

ធានី ៖ គាត់ស្លាប់ដោយសារអីគេ?

ម៉ាន ៖ គាត់ស្លាប់កាលបាញ់គ្នានោះ ។

ធានី ៖ ក្នុងសង្គ្រាម?

ម៉ាន ៖ មិនដឹងថាម៉េចទេ ដោយសារបាញ់គ្នានឹង មិនដឹងដែរ ។

ធានី ៖ ហើយបន្ទាប់មកទៀតម៉េចទៀតមីង ពេលគ្រួសារស្លាប់ហើយ?

ម៉ាន ៖ គ្រួសារស្លាប់ហើយ នៅមិនដឹងឆ្នាំប៉ុន្មានចេញមកនឹងវិញ ។

ធានី ៖ ចេញមកនៅភូមិយើងវិញ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ មីងរកនឹកមើលប៉ុន្មាន?

ម៉ាន ៖ មិនដឹងប៉ុន្មានទេ បើពូគាត់សម្លាស់ដឹងថាប៉ុន្មានប៉ុននឹងឯង មកជាមួយគ្នាទាំងអស់ តែចេញមកអត់ចេញមួយទេ ចេញទាំងអស់ ។

ធានី ៖ អីចឹងកាល៩០នឹងប្រជាជនហើយនឹងអ្នកភូមិអីមកនៅភូមិនេះវិញមកម៉ាឡៃ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ហើយមកម៉ាឡៃដំបូងមីងឃើញម៉េចដែរ?

ម៉ាន ៖ យី! ឃើញម៉េចទេ សុទ្ធតែគ្រាប់មីនៗនិយាយពីរបង២ជាន់ មីននៅទាំង២ជាន់ ហើយមីនមកនេះពាសពេញព្រៃមីន ។

ធានី ៖ មីននឹងមកពីណាវិញ?

ម៉ាន ៖ មីននឹងតាមការវិភាគទៅ ថាខាងក្នុងវៃមកដាក់ ដល់យើងប្រានខាងក្នុងទៅយើងដាក់ម៉ាកំរាស់ទៀត ដាក់ការពារគ្នាទៅវិញទៅមក ។ យើងមកនៅប្រានមកដល់ភ្នំយាយសំអីចឹង យើងដាក់កន្លែងយាយសំដាក់មីនរបស់យើងនៅលើភ្នំយាយសំ ហើយកាលមកពីក្នុងមក វៀញយើងទៅ

ចូលដីថៃ ក៏គាត់ធ្វើរបងលួស២ជាន់ ដាក់មីនឡើងដូចគេស្ទូងអីចឹង ។ មកនេះដើរ ស្នាមជើងបានហ៊ានដើរទៅមុខ ជាន់ឲ្យចំស្នាមគេបានហ៊ាន ។

ធានី : ជាន់ខុសខ្វាចមានបញ្ហា?

ម៉ាន : ហ្អឹងហើយ ។ ហើយគេមកមុនដឹបូងតាមកង១ទ័ពអង្គភាពប្ដីយើងមកនៅតាមគេ ដូចខ្ញុំអ្នកម៉េម៉ាយ គេអ្នកមានប្ដីគេទៅនៅត្រង់ណា យើងចេះទៅនៅនឹងគេទៅ ហើយដល់នេះទៅចេះនៅវែកឲ្យនៅបួន់ទៅ ។

ធានី : មីងមកនៅនឹងគេមួយទៅ?

ម៉ាន : ហ្អឹងហើយ ដូចថាកន្លែងនឹងគេមានប្ដី យើងមកនៅកន្លែងនេះ នៅជាប់ស្រយាប១គ្នាតាម១ ដូចថាបងប្អូនដែរនឹង ។ ដល់ពេលយើងមកនៅអីចឹងចេះនៅបែកគ្នារស់ ។

ធានី : ហើយដល់ពេលមីងមកនៅអីចឹង អត់មានមីនមានអីទៀតទេ?

ម៉ាន : មីនមាន មីនដោះពួកកងទ័ព ពួកទាហាននឹងគាត់ដោះទៅ គាត់ដោះចែកជូនប្រជាជនខ្លះទៅ យើងក៏ដូចខ្ញុំអីបានដីតិចតួចនៅភូមិចេះតែរាវខ្លួនឯងខ្លះទៅ ។

ធានី : មីងចេះរាវមីនដែរ?

ម៉ាន : ចុះយើងរៀន១២ឆ្នាំកាលនៅទ័ព ។

ធានី : រាវនឹងធ្វើម៉េចខ្លះ?

ម៉ាន : យើងរាវស៊ើអីចឹងទៅយើងដូចឃើញមីន យើងយកក្រលាស់វាយើងនៅភ្នែកភ្លឺមើលក្រលាស់ បើថាក្រលាស់នឹងវាចោទណាស់ យើងអត់ហ៊ានធ្វើអីទេ យើងកំទេចវាហើយ ។ បើថាយើងអាចរុញម្ជុរនឹងបាន ដៃយើងឲ្យនឹង រុញម្ជុរនឹងបាន រុញឲ្យកីបចូលក្នុងប្រហោងចន្លោះនឹងបានបាននឹងយើងរួចខ្លួនហើយ ។

ធានី : រុញកីមនឹងអត់ផ្ទុះទេ?

ម៉ាន : អានឹងវាមានបង្កោលវា ។

ធានី : អានឹងមីនស្អីគេ?

ម៉ាន : មីនស្អីក៏ដោយ វាមានបង្កោលអីចឹង បើអាគន្លឹះរំស័រវា ហើយអាម្ជុរនេះអីចឹងមក ។

ធានី : យើងកីបឲ្យត្រឹមរំស័រ អត់ចូលដល់ក្នុងពេកទេ?

ម៉ាន : អឺ! ដល់វាហួត យើងដាក់យើងហូតក្រលាស់១មកពាក់កណ្ដាលរំស័រនៅគងរំស័រ បើថាពាក់កណ្ដាលហើយ គេអត់ហ៊ានទេ ។ បើថានៅគងរំស័តអីចឹង កន្លែងនេះមានបង្កោលតូចប្រហោងបង្កោលនឹងសម្រាប់ដាក់គន្លឹះវាញ៉ុកវិញទៅមកអីចឹង ។ ដូចមានបង្កោល២ចេះ ហើយគន្លឹះម្ជុរវាចេះ គន្លឹះម្ជុរមួយខាងនេះ ។

ធានី : ហើយមីននឹងជាន់នឹងជើងស្លាប់នឹង?

ម៉ាន : អាជាន់នឹងដាក់ដោយខ្លួន ។

ធានី : មីនមីងនិយាយ មីនអីគេ?

ម៉ាន : អានឹងមីនអន្ទ្រាក់ ទាក់នឹងជើងវារបូត ។

ធានី : ទាក់ខ្សែរបូតផ្ទុះ?

ម៉ាន : ហ្នឹងហើយ អាមីនយើងជាន់លើទំងន់ អាមួយមីនគោន អានឹងដល់គោនវាបានផ្ទុះ ។

ធានី : យើងល្មមៗអត់អីដែរ?

ម៉ាន : អត់អីទេមនុស្សជាន់អត់អីទេ អាទៅគ្នាច្រើននឹងបើសិនណាជាត្រូវអាមីនយើងជាន់ទំងន់មនុស្ស ដូច៥០-៦០គីឡូ ត្រូវផ្ទុះៗហើយ សត្វជាន់ក៏ផ្ទុះដែរ អានឹងដាក់ជាមនុស្ស មួយដាក់យកឡាន ។

ធានី : មីងឧស្សាហ៍ឃើញមានមីនអ្នកខ្លះជាន់ប៉ះមីន?

ម៉ាន : ឃើញតើប្អូន ឃើញ គ្រោះថ្នាក់នឹងមីនច្រើនណាស់ ស្លាប់ពិការ កំបុតជើងៗសុទ្ធតែរាវមីន ម៉ាដូរជាយដែន ។

ធានី : រាវមីនដែរ?

ម៉ាន : រាវ ។

ធានី : រាវទៅប៉ះផ្ទុះ?

ម៉ាន : ចា៎ះ!

ធានី : មិនមែនមកពីគាត់ដើរជាន់ផ្ទុះ?

ម៉ាន : មិនមែនទេ ធ្វើឲ្យស្រឡះទុកឲ្យកូនប្រពន្ធនៅនឹងប៉ះទៅខ្វាក់ភ្នែកទៅ ខ្លះកំបុតដៃ-ជើងទៅ ។

ធានី : ហើយម៉េចទៀតទៅ អ្នកខ្លះរាវមីន កាប់ឆ្ការនៅខ្លួនឯងនៅម៉េចទៀត?

ម៉ាន : នៅនឹងរហូត នៅទាល់តែយើងវៃគ្នាយូរៗទៅបានផ្សះផ្សាគ្នានឹង ។

ធានី : ឆ្នាំប៉ុន្មានផ្សះផ្សាគ្នា?

ម៉ាន : អឺ! ខ្ញុំមិនសូវចាំទេ ដល់មានកូនមានចៅអីគិតរឿងកូនរឿងចៅ រឿងអត់រឿងឃាត់ យើងមេម៉ាយផង មិនដឹងជាផ្លូវណាទៅណោវង្វេងវង្វាន់អស់ហើយ ។ ខ្ញុំដល់មានកូនមានប្ដីវង្វេងភ្លេចអស់ មិនដឹងឆ្នាំណាឆ្នាំអី ភ្លេចអស់ ។

ធានី : អត់ចាំទេ?

ម៉ាន : អឺ! ទោះយ៉ាងណាមិនដឹង លែងគិតលែងអីហើយ គិតពីផ្នែកម៉ាពោះ រស់ម៉ាខ្លួន ។

ធានី : មីងអត់ដឹងថាអ្នកណាគេអ្នកកកើតម៉ាឡៃនឹង រៀបចំនៅម៉ាឡៃនឹងដំបូង?

ម៉ាន :  មានតែបងភាពនឹងឯង កងពល ។

ធានី :  គាត់អីភាព?

ម៉ាន :  អូយ! អត់ដឹងទេ ឮថាលោកភាព មិនដឹងគាត់ឈ្មោះអីទេ ។

ធានី :  គាត់នឹងអ្នកផ្ដើមឲ្យមានម៉ាឡៃនឹង?

ម៉ាន :  ចា៎ះ!

ធានី :  ចុះអ្នកណាធំជាងភាព?

ម៉ាន :  មិនដឹងអ្នកណាទេ កន្លែងនឹងមានតែបងភាពនឹងឯងគ្រប់គ្រងខាងទ័ពនឹង ដូចគ្រប់គ្រងខាងយើងនឹងឯង ទាំងអស់នឹងឯង ។ តែគ្រប់គ្រងខាងទ័ព ប្រពន្ធគាត់ក៏នៅនឹង វាអីចឹងតែមួយ ។

ធានី :  មីងអត់ដឹងថាសន្តិភាពពេលណា?

ម៉ាន :  អូយ! អត់ដឹងទេ ។

ធានី :  អត់ចាំ?

ម៉ាន :  អត់ចាំទេ គេអ្នកធ្វើដូចពូគាត់សម្ភាសន៍មុនអីបានគាត់ដឹង នឹងគាត់អ្នកកាន់កាប់យើងប្រជាជន អត់ដឹងទេ ដឹងតែពីរស់នៅ ។

ធានី :  ចុះពេលណាគេឲ្យយើងរកស៊ីខ្លួនឯង?

ម៉ាន :  គេផ្ដាច់ខ្លួនហើយ ។

ធានី :  ផ្ដាច់ខ្លួនពេលណា?

ម៉ាន :  អាផ្ដាច់ខ្លួនដែលត្រូវជាមួយលោកហ៊ុន សែននឹង ។

ធានី :  មីងចាំឆ្នាំ?

ម៉ាន :  អត់មានចាំទេ ថាអត់ចាំ អត់ដឹងរឿងចាំសោះ ។

ធានី :  មីងរាល់ថ្ងៃប្រកបរបរអីដែរ?

ម៉ាន :  អត់មានអីទេ ស៊ីឈ្នួលគេសោះ អត់មានស្រែ មានចំការ មានទីផ្ទះនៅ ចុះយើងមេម៉ាយហើយ សុទ្ធតែមីន រកដីមកពីណា ។ ហើយនៅម៉ាបាតផ្ទះ មានដីតិចតួចក៏គេដណ្ដើមលិចដណ្ដើមកើត ។

ធានី :  ដូចថាមីងនៅសម័យខ្មែរក្រហម មីងធ្លាប់ជួយពីណាគេ នៅចន្លោះពេលមីងធ្វើអ្នកតម្បាញផងធ្វើក្រឡឹងផង?

ម៉ាន :  ជួយអ្នកណា?

ធានី :  ដូចថាជួយទំនុកបំរុង ជួយឲ្យរួចជីវិតមានទេ?

ម៉ាន :  មានតើប្អូន ។

ធានី ៖ អ្នកណាគេ?

ម៉ាន ៖ ជួយឈ្មោះអឿននឹងមួយ អានឹងគេតាមវ៉ៃមិនដឹងមូលហេតុស្រី ។ តាមវ៉ៃចូលមកក្នុងនេះខ្ញុំនឹង ចូលក្នុងផ្ទះខ្ញុំ ក្នុងបន្ទប់ខ្ញុំ ។ មកក៏សុំសំណាក់រោងចក្រឲ្យនៅបណ្ដោយ ។

ធានី ៖ មីងសុំ?

ម៉ាន ៖ ចា៎ះ! សុំ ។

ធានី ៖ អត់អីទេ មីងសុំគេអត់ថាអី?

ម៉ាន ៖ អត់ថាអីទេ ប៉ុនគេថាកុំឲ្យលេចមុខឲ្យអ្នកតាមនឹងគេឃើញ ។

ធានី ៖ មីងសុំគណៈរោងចក្រអ្នកណាគេឈ្មោះអី?

ម៉ាន ៖ ឈ្មោះ ពូអីនៅសំណង់ ។

ធានី ៖ ពូដាន?

ម៉ាន ៖ ចា៎ះ! ពូដាននឹងឯង ។

ធានី ៖ សុំគាត់នឹង ហើយពូដាន គាត់អត់ថាអីដែរ?

ម៉ាន ៖ អត់ថាអីទេ គ្រាន់ថាឲ្យលាក់ខ្លួនទៅ ហើយនៅនឹងទៅ ។

ធានី ៖ ដឹងហេតុអី គេមានប្រាប់មីងថាហេតុអីៗ?

ម៉ាន ៖ កាលនឹងពូមិត្តនឹង អឿននឹងនិយាយថា គេពិសោធន៍ក្នុងការដាំដុះ ដូចថានៅក្នុងប្រជាជននោះ គេធ្វើកសិករ(កសិកម្ម) ។

ធានី ៖ អឿននឹងមកពីណាវិញ?

ម៉ាន ៖ ដឹងមកពីណាទេ អន្តភាព ណាទេ គេប្រាប់ដែរ ចេះយូរទៅវាភ្លេចហើយ ។

ធានី ៖ គាត់នៅម្តុំផ្ទះក្បែររោងចក្រមីង?

ម៉ាន ៖ ចា៎ះ! នៅម្តុំក្បែរនឹង គេវ៉ៃឡើងហើមមុខ ហើមមាត់អស់ ដល់វ៉ៃហើយដល់នេះទៅដឹងម៉េចរត់ រួចមកដូចថាសន្លប់មិនដឹង គេថាងាប់ ។ ដល់ហើយគេថាងាប់ទៅៗបាត់ទៅ ។ ថាកាលនឹងដាំ ល្ហុងវានឹងអ្នកនៅចំការល្ហុង ។ ដាំល្ហុងដល់បានត្រឹមទ្រូងល្ហុងល្អ គេយកកាំបិតវះហើយគេញ៉ុក អាខ្ទាញ់គោឃើងសម្រាប់ដាក់ឡាន-ម៉ាញ៉ុងម៉ូតូ ។ ម្នាក់នឹងសួរថា ចុះបងឯង កាលនឹងគេហៅ មិត្តបងៗ គេសួរប្រធានគេនឹង ដល់នេះទៅគេថាយើងក្បត់ គេថាយើងប្រឆាំងគេ ។ ដល់ នេះហើយ គេក៏តាមវ៉ៃវាទៅ ។

ធានី ៖ ហើយក្រោយមកទៀតគេអត់រករឿងទេ ព្រោះគេគិតថាគាត់ស្លាប់ហើយ?

ម៉ាន ៖ ហ្នឹងហើយ គេថាស្លាប់ហើយ ។

ធានី ៖ ម៉េចបានមីងជួយសង្គ្រោះគាត់?

ម៉ាន ៖ ចុះមនុស្សជាមនុស្ស សង្គ្រោះទៅ បើថាយ៉ាងណា ។

ធានី ៖ គេអត់ថាមីងប្រឆាំងទេ មីងជួយគេ?

ម៉ាន ៖ អត់កន្លែងរោងចក្រខ្ញុំនឹងក៏គេចិត្តល្អ ។

ធានី ៖ គេជួយគ្នា?

ម៉ាន ៖ហ្នឹងហើយ ។

ធានី ៖ មានពេទ្យមានអី?

ម៉ាន ៖ មានតើ ។

ធានី ៖ មានពេទ្យគេជួយមើលដែរ?

ម៉ាន ៖ ហ្នឹងហើយ កាលនឹងមីងនៅនឹង មីងដេកពេទ្យកន្លែងក្តារបន្ទះកន្លែងតាខ្មៅ ។

ធានី ៖ កាលនឹងមីងដេកពេទ្យតាខ្មៅទេ មិនមែននៅជាងក្រឡឹងទេ?

ម៉ាន ៖ មិនមែនទេ ។

ធានី ៖ កាលពេលមីងជួយសង្គ្រោះគាត់នឹង?

ម៉ាន ៖ អានឹងនៅរោងចក្រថ្មី មិនមែននៅតម្បាញទេ ។

ធានី ៖ រោងចក្រក្រឡឹង ប៉ុន្តែមីងមកគេងនៅ?

ម៉ាន ៖ នៅនឹងឯង នៅរោងចក្រក្រឡឹងនឹងឯង ។

ធានី ៖ ចុះមីងថាជួយសង្គ្រោះគេ?

ម៉ាន ៖ នៅនឹងឯង នៅកន្លែងគីឡូលេខ៦កន្ទះនឹងអត់ ។

ធានី ៖ ចុះមីងថាដេកពេទ្យនៅតាខ្មៅម៉េច?

ម៉ាន ៖ ចុះអគ្គភាព ពេទ្យគេនៅនឹង ។

ធានី ៖ ពេទ្យនឹងមកនៅកន្លែងរោងចក្រនឹង ប៉ុន្តែគាត់មកពីតាខ្មៅ?

ម៉ាន ៖ ចំមើលពេទ្យនឹង អគ្គភាពកន្លែងរោងចក្រនឹង ពេទ្យគេមូលដ្ឋានពេទ្យដែលប្រចាំរោងចក្រនឹងនៅតាខ្មៅ ។

ធានី ៖ ពេទ្យនឹងមកនៅរោងចក្រមីងទេ ដែលជួយសង្គ្រោះនឹង?

ម៉ាន ៖ នៅនឹងហ្នឹងឯង បញ្ជូនទៅនឹង ។

ធានី ៖ គេបញ្ជូនទៅពេទ្យតាខ្មៅនឹង?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ឲ្យតែឈឺ មីងបញ្ជូនអ្នកជម្ងឺនឹង ពីកន្លែងរោងចក្រនឹងទៅពេទ្យតាខ្មៅ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ហើយមីងជួយមើលថែដែរ?

ម៉ាន ៖ អត់ទេ គ្រាន់បញ្ជូនទៅ ឲ្យពេទ្យមើល ។

ធានី ៖ សុំប្រធានរោងចក្រ ថាមីងសុំឲ្យគាត់នៅជាមួយ?

ម៉ាន ៖ ចា៎ះ!

ធានី ៖ ម៉េចដែរមីង តាំងពីនឹងមកមីងជួយសង្គ្រោះគាត់ គាត់ដែលមកសួរសុខទុក្ខមីង?

ម៉ាន ៖ មកៗរត់មកនៅក្នុងព្រៃនឹង ដល់ពេលនេះជម្ងឺគាត់ឈឺស្លាប់ហើយ ស្លាប់ដដែល ។

ធានី ៖ ដោយសារអីគេ?

ម៉ាន ៖ ឈឺ ។

ធានី ៖ ឈឺអីគេ?

ម៉ាន ៖ ឈឺអត់ ហើយដល់ពេលវាមូសខាំវាគ្រុនចាញ់ទៅ វាមានគ្រុនចាញ់ទៅ យើងអត់មានថ្នាំសង្កូវដង ស្លាប់ទៅ ។

ធានី ៖ ហើយអត់ដឹងថាបងស្រីនឹងគាត់មកពីណាៗ?

ម៉ាន ៖ មកពីល្វាអែម ស្រុកកំណើតគាត់នៅល្វាអែម ។

ធានី ៖ អត់ដឹងឪពុកម្ដាយគាត់ឈ្មោះអី?

ម៉ាន ៖ អត់ ។

ធានី ៖ គាត់មានផ្ដែផ្ដាំអី?

ម៉ាន ៖ និយាយទៅវាផ្ដែផ្ដាំដែរ ដល់ពេលយើងចាស់ហើយ យើងភ្លេចហើយ ។ អីចឹងបានខ្ញុំថា មិនដឹងសម្ភាសន៍យ៉ាងម៉េច បើខ្ញុំភ្លេចឡើងភ្លេចម្ញឹងៗ ។

ធានី ៖ មីងគិតថាផ្ទះផ្សា ត្រូវរូវគ្នា គួរតែនៅជិតគ្នាឬនៅឆ្ងាយគ្នាបានល្អ ពីរនឹងមួយណាល្អជាង?

ម៉ាន ៖ ផ្ទះផ្សានៅឆ្ងាយក៏ល្អ នៅជិតក៏ល្អ ។

ធានី ៖ មីងគិតថាមួយណាល្អជាង?

ម៉ាន ៖ នៅជិតល្អជាង ។

ធានី ៖ ហេតុអី?

ម៉ាន ៖ នៅជិតវាទំនាក់ទំនងគ្នាបាន ដល់នៅឆ្ងាយវារៀងដូចថានៅឆ្ងាយវាដូចបងប្អូនយើង ទំនាក់ទំនងគ្នាក៏វាមិនបានដែរ នៅឆ្ងាយយូរៗម្ដង ។ បើយើងនៅជិតគ្នា យើងចេះទំនាក់ទំនងគ្នារាល់ថ្ងៃ យើងអាចដឹងចិត្តដឹងថ្លើមគ្នាណា ។

ធានី ៖ មីងមាននៅសល់រូបថតចាស់ជំនាន់៨០ជាង ឬតាំងពី៧៥?

ម៉ាន ៖ អត់ទេ អត់មានរូបថតនៅខាងនឹង មិនមានណា ។

ធានី ៖ មីងមានអីចង់សួរខ្ញុំវិញ ឬចង់បន្ថែមអីដែរខ្ញុំអត់សួរ?

ម៉ាន ៖ អត់ទេះសួរ ។

ធានី ៖ អរគុណមីងច្រើន ដែលបានអនុញ្ញាតិឲ្យសម្ភាសន៍ ។

«ចប់»